ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០៧៧៨ ឧ.វ.ប.ន. សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- យោងតាមតម្រូវការការងារចាំបាច់

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត **លេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ** ដែលហៅកាត់ថា **លេខាធិការដ្ឋាននៃ គ.ស.អ.ស.ក.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- លោកជំទាវ **ពៅ ចរលក្ខណ៍** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២- លោក **ចាតសូ សុភ័ក្រ** | អគ្គនាយករងកិច្ចការទូទៅ | អនុប្រធាន |
| ៣- លោក **រាម ច័ន្ទវណ្ណា** | អគ្គនាយករងសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម | អនុប្រធាន |

| | | | |
|---|---|---|---|
| ៤- | លោក **ឆាយ រាម័ន្ត** | អគ្គនាយករងវាយតម្លៃទទួលស្គាល់នៃកម្ពុជា | អនុប្រធាន |
| ៥- | លោក **គង់ បញ្ញារិទ្ធ** | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |
| ៦- | លោក **ចឹក ទិចិត្រ** | អគ្គនាយករងវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |
| ៧- | លោកស្រី **សេង ម៉ូលីកា** | ប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៨- | លោក **ទឹម សេរីវុធ** | អនុប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៩- | លោក **ស៊ុនសី សិរីទេវៈទេព** | សមាជិកខុទ្ទកាល័យ | សមាជិក |
| ១០- | លោកស្រី **សាង សុគន្ធី** | អនុប្រធាននាយកដ្ឋានផែនការនិងជំរុញ ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម | សមាជិក |
| ១១- | លោកស្រី **ឃុន រំយោល** | អនុប្រធានមជ្ឈមណ្ឌលផលិតភាពជាតិ | សមាជិក |
| ១២- | លោក **ផាត សំអាន** | អនុប្រធាននាយកដ្ឋានព័ត៌មាន | សមាជិក |
| ១៣- | លោកស្រី **យឹន វលក្ខ័ណា** | អនុប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ សមត្ថភាពអង្គភាពពិសោធន៍ | សមាជិក |
| ១៤- | លោកស្រី **ព្រាប ឆោមសុគន្ធា** | ជំនួយការ | សមាជិក |

**ប្រការ២.-**

**លេខាធិការដ្ឋាននៃ** គ.ស.អ.ស.ក. មានតួនាទីជាសេនាធិការជូន គ.ស.អ.ស.ក. និងមានភារកិច្ចដូចតទៅ៖

- ជាអង្គភាពបង្គោលសម្រាប់សម្របសម្រួលអន្តរក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- សម្របសម្រួលការរៀបចំផែនការសកម្មភាពអនុវត្តលម្អិត របស់ក្រសួងស្ថាប័ន
- ណែនាំ និងតម្រង់ទិសការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះរបស់ក្រសួងស្ថាប័ន
- ជំរុញការផ្សព្វផ្សាយ ពីគោលនយោបាយ កម្មវិធី យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ពិនិត្យ និង សិក្សាទិដ្ឋភាពគោលនយោបាយ ច្បាប់លិខិតបទដ្ឋានគតិយុត្តដើម្បីជំរុញការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- រៀបចំក្របខណ្ឌ និងយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ទទួលរាល់សំណូមពរនានារបស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដើម្បីដាក់ជូន **គ.ស.អ.ស.ក.** ពិនិត្យ និងដោះស្រាយបញ្ហាប្រឈម
- រៀបចំកិច្ចប្រជុំ គ.ស.អ.ស.ក. តាមការណែនាំរបស់ប្រធាន គ.ស.អ.ស.ក.
- រៀបចំកំណត់ហេតុ ធ្វើរបាយការណ៍រាល់កិច្ចប្រជុំ និងធ្វើសេចក្តីជូនដំណឹងស្តីពីការសម្រេចរបស់ គ.ស.អ.ស.ក. និងរបស់រាជរដ្ឋាភិបាលជូនសមាជិក សមាជិកា គ.ស.អ.ស.ក.
- រៀបចំចងក្រងរបាយការណ៍ និងសមិទ្ធកម្មគន្លឹះរបស់ **លេខាធិការដ្ឋាននៃ** គ.ស.អ.ស.ក. ជូនប្រធាន គ.ស.អ.ស.ក. តាមពេលកំណត់
- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ គ.ស.អ.ស.ក. តាមការសម្រេចរបស់ប្រធាន គ.ស.អ.ស.ក.
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ គ.ស.អ.ស.ក. ។

**ប្រការ៣.-**

ប្រភពធនធានសម្រាប់ទ្រទ្រង់ **លេខាធិការដ្ឋាននៃ គ.ស.អ.ស.ក.** រួមមាន៖ ប្រភពថវិកាជាតិ ថវិកាពីដៃគូអភិវឌ្ឍន៍ និងថវិកាបានមកពីប្រភពស្របច្បាប់ផ្សេងទៀត។

**ប្រការ៤.-**

**លេខាធិការដ្ឋាននៃ** គ.ស.អ.ស.ក. អាចមានជំនាញការ ឬនិងទីប្រឹក្សាបច្ចេកទេសមួយចំនួនតាមការចាំបាច់។

**លេខាធិការដ្ឋាននៃ** គ.ស.អ.ស.ក. មានសិទ្ធប្រើប្រាស់ត្រាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ( ឧ.វ.ប.ន.) សម្រាប់បំពេញការងាររបស់ខ្លួន។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

គ្រប់ថ្នាក់ដឹកនាំក្រសួង នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង ឧ.វ.ប.ន. ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៥កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤

**រដ្ឋមន្ត្រី និងជា**

**ប្រធានគណៈកម្មាធិការសម្របសម្រួល**

**ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ**

**ហែម វណ្ណឌី**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៦ “ ដើម្បីអនុវត្ត ”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ